(ការជូនដំណឹង.seattle.រដ្ឋាភិបាល/ទីតាំងជម្រកនៅនឹងកន្លែង)

**ការណ៍ពិត ៖** អាជ្ញាធរបានចេញសេចក្តីបង្គាប់ឱ្យដាក់ទីតាំងជម្រកនៅនឹងកន្លែង សម្រាប់តំបន់មួយចំនួន នៅក្នុង Seattle ។ នេះមានន័យថា ស្ថានភាពមានសុវត្ថិភាពជាង ដោយការនៅនឹងកន្លែង ហើយជៀសវាង គ្រោះថ្នាក់ដែលអាចកើតមានពីខាងក្រៅ ។ អាចគ្មានព័ត៌មានផ្តល់ជូនឱ្យបានមុន សម្រាប់ សេចក្តីលំអិតបន្ថែមអំពីរឿងដែលកំពុងកើតមានឡើងនោះទេ ។

**អ្វីដែលត្រូវធ្វើ ៖**

- ត្រៀមលក្ខណៈ ដើម្បីនៅខាងក្នុងផ្ទះ ។ នាំក្រុមគ្រួសារ និងសត្វចិញ្ចឹមរបស់លោកអ្នក ឱ្យនៅក្នុងផ្ទះ ។ បិទទ្វារ បង្អួច និងឡដុតកំដៅ ហើយចាក់សោ ។ ដាក់កន្សែងពោះគោសើម នៅច្រកទ្វារ ចូល និងច្រកផ្សេងៗ ទៀត ដែលអាចឱ្យកំសួលពីខាងក្រៅ ចូលបាន ។
- បិទកង្ហារ ម៉ាស៊ីនត្រជាក់ និងប្រព័ន្ធកំដៅដោយខ្យល់ជំរុញ ។
- ត្រៀមលក្ខណៈ នឹងធ្វើការកែច្នៃ ហើយប្រើអ្វីដែលលោកអ្នកមាននៅក្នុងដៃ ដើម្បីបិទរន្ធចន្លោះ ដើម្បីបិទបាំងខ្លួនលោកអ្នក ពីខ្យល់ខាងក្រៅ ។
- នៅក្នុងផ្ទះបិទជិត រហូតដល់ពេលអាជ្ញាធរមូលដ្ឋានប្រាប់ថា មានសុវត្ថិភាព អាចចាកចេញ ពីលំនៅដ្ឋាន ឬអាគារ របស់លោកអ្នកបាន ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- ***ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។***

**តំណរបណ្តាញដែលមានប្រយោជន៍ ៖**

http://www.kingcounty.gov/safety/prepare/residents-business/PersonalPreparedness/ShelterInPlace.aspx

http://www.ready.gov/shelter

http://emergency.cdc.gov/preparedness/shelter/